# ផលិតកម្មនិងការផ្គត់ផ្គង់ពូជដំណាំ

ការធ្វើពិពិធកម្មប្រព័ន្ធផ្គត់ផ្គង់គ្រាប់ពូជស្រូវ គឺជាអាទិភាពខ្ពស់មួយ ដើម្បីបង្កើតនូវទីផ្សារប្រកួតប្រជែង និងបង្កើនជម្រើសនៃប្រភេទពូជសម្រាប់កសិករ និងអ្នកផ្គត់ផ្គង់

តាមកិច្ចសន្យា (Contract Farming) សម្រាប់ផលិតកម្មពូជដំណាំ នឹងត្រូវលើកទឹកចិត្តឱ្យបានខ្លាំងក្លា ព្រោះវាជាយន្តការមួយក្នុងការជំរុញការអភិវឌ្ឍន៍វិស័យផលិតកម្មពូជដំណាំ

គាំទ្រពេញទំហឹងចំពោះការចូលរួមពីសំណាក់រោងម៉ាស៊ីនកិនស្រូវ និងសមាគមម៉ាស៊ីនកិនស្រូវនៅក្នុងសង្វាក់ផ្គត់ផ្គង់គ្រាប់ពូជ ដើម្បីលើកកម្ពស់ផលិតកម្មប្រភេទពូជដែលមានតម្រូវការច្រើនជាងគេ និងកាត់បន្ថយភាគរយនៃអង្ករចម្រុះនៅលើទីផ្សារ

- ឯកសារគម្រោងផលិតកម្មពូជដំណាំប្រកបដោយជោគជ័យ
- ការរៀបចំផែនការផលិតកម្មពូជស្រូវ
- ផែនការសកម្មភាពសម្រាប់ជម្រុញការនាំចេញអង្ករ
- ការលើកកម្ពស់ផ្នែកអ្នកផលិតពូជជាផ្លូវការ

# ផ្នែកទី ៨
# ការនាំចូលគ្រាប់ពូជដំណាំ

**ពូជនាំចូល**

- ធ្វើពិពិធកម្មនៃប្រភពពូជសម្រាប់ធ្វើឲ្យប្រសើរឡើងផលិតកម្មនិងទីផ្សារ
- ធ្វើឲ្យមានភាពងាយដល់ដំណើរការនាំចូល
- បំពេញតាមលក្ខខណ្ឌភោត្តគាមអនាម័យ និងស្តង់ដាពូជដំណាំ។

**ពូជនាំចេញ**

- ឱកាស សម្រាប់ការនាំចេញពូជដំណាំក្នុងតំបន់
- ការបង្កើតនៃមន្ទីរពិសោធន៍សម្រាប់ធ្វើតេស្តសាកល្បងពីគុណភាពពូជដំណាំ។

# ផ្នែកទី ៩
# ពូជបន្លែ

ពូជនាំចូល

- មានស្លាកសញ្ញាវេចខ្ចប់ត្រឹមត្រូវជាអក្សរខ្មែរ
- ស្តង់ដាគុណភាពគ្រាប់ពូជដំណាំ
- បោះពុម្ពបញ្ជីព័ត៌នៃពូជដំណាំនាំចូលជាអក្សរខ្មែរ
- លក់ចែកចាយលើទីផ្សារ ត្រូវស្ថិតក្នុងសំបកវេចខ្ចប់ ដើមត្រឹមត្រូវ

<u>ការវេចខ្ចប់ក្នុងតំបន់នៃពូជនាំចូល</u>

រាល់ការវេចខ្ចប់សារជាថ្មីនៅក្នុងស្រុកនូវរាល់ពូជដំណាំនាំចូល ដែលពុំទាន់ធ្វើការវេចខ្ចប់ ត្រូវផ្តល់ព័ត៌មានដល់អគ្គនាយកដ្ឋានកសិកម្ម ដើម្បីធ្វើការត្រួតពិនិត្យគុណភាព និងលក្ខណៈបច្ចេកទេសនៃការវេចខ្ចប់ សំដៅធានាបាននូវគុណភាពត្រឹមត្រូវស្របតាមស្តង់ដារបច្ចេកទេស។

# ផ្នែកទី ១០
# ពូជដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម

**ពូជដំណាំរួមផ្សំ**

- ប្រភេទដំណាំទាំងនេះមិនសូវទទួលបានការចាប់អារម្មណ៍ពីក្រុមហ៊ុនលក់ពូជដំណាំទេ
- គួរមានការលើកទឹកចិត្តឱ្យមានការដាក់បញ្ចូលពូជដំណាំប្រភេទនេះ ទៅក្នុងប្រព័ន្ធផលិតកម្ម
- គួរមានការលើកទឹកចិត្តឱ្យមានការដាក់បញ្ចូលពូជដំណាំប្រភេទនេះ ទៅក្នុងប្រព័ន្ធផលិតកម្ម

**ដំណាំឧស្សាហកម្ម**

- ជំរុញការណែនាំអនុវត្តនូវប្រព័ន្ធគ្រប់គ្រង ការបង្កាត់ និងការផ្សាំ សំដៅបង្កើនគុណភាព និងសុខភាពនៃបំណែកពូជដំណាំដើម្បីបង្កើនផលិតកម្ម
- អភិវឌ្ឍន៍នៃគោលការណ៍បច្ចេកទេស

# ផ្នែកទី ១១
# ការការពារពូជដំណាំ

- មានសារៈសំខាន់ចំពោះអ្នកវិនិយោគឯកជន ក្នុងវិស័យបង្កាត់ពូជដំណាំក៏ដូចជាការផ្សព្វផ្សាយពូជថ្មីនៃដំណាំនាំចូលពីបរទេស
- ប្រតិបត្តិតាមភាពសមាជិកនៃ WTO

អ្នកបង្កាត់ពូជដំណាំដែលមានបំណងការពារពូជថ្មីនៃដំណាំ ត្រូវដាក់ឯកសារ និងពាក្យស្នើសុំទៅកាន់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

ការងារបច្ចេកទេសសម្រាប់វាយតម្លៃពូជដំណាំថ្មី(DUS) នឹងត្រូវអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ផ្តល់សិទ្ធិការការពារ

# ផ្នែកទី ១២
# លិខិតបទដ្ឋានសម្រាប់ទស្ស័យពូជដំណាំ និងការត្រួតពិនិត្យគុណភាព

**អាទិភាព:**

- ស្តង់ដាគុណភាពគ្រាប់ពូជ
- ដំណើរការចុះបញ្ជីការពូជដំណាំ
- ប្រកាសស្តីពីការធ្វើពាណិជ្ជកម្មពូជដំណាំ
- ស្តង់ដាស្លាកសញ្ញា

- ការដាក់ឈ្មោះជំនាន់ពូជដំណាំ គួរស្ថិតក្រោមការត្រួតពិនិត្យ និងកំណត់ស្តង់ដារពូជដំណាំដោយអគ្គនាយកដ្ឋានកសិកម្ម
- ការណែនាំពីស្តង់ដារនិងស្លាកសញ្ញាលើសំបកវេចខ្ចប់ពូជដំណាំ ពិសេសសម្រាប់ពូជស្រូវគឺជាការចាំបាច់

- អគ្គនាយកដ្ឋានកសិកម្ម នឹងពិនិត្យតាមដានគុណភាពពូជដំណាំនៅលើទីផ្សារ និង វាយតំលៃស្តង់ដារគុណភាពពូជដំណាំ
- បង្កើតមន្ទីរពិសោធន៍ពូជដំណាំឯករាជ្យមួយគឺជាការចាំបាច់
- រៀបចំពិធីសារធ្វើតេស្តសាកល្បងដំណុះស្តង់ដាសំណាក់

# ផ្នែកទី ១៣
# ការអប់រំនិងការបណ្តុះបណ្តាល

- គាំទ្រឱ្យមានការដាក់បញ្ចូលមុខជំនាញដែលពាក់ព័ន្ធនឹងពូជដំណាំ ព្រមទាំងឧស្សាហកម្មពូជដំណាំ ទៅក្នុងកម្មវិធីសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលជាន់ខ្ពស់ ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ និងការបណ្តុះបណ្តាលខ្លី
- ជំរុញការគាំទ្រតាមរយៈយន្តការសមស្របនានា ទៅដល់មន្ទីរកសិកម្មខេត្ត ស្ថាប័នផលិតពូជដំណាំ និងអង្គការមិនមែនរដ្ឋាភិបាលដោយធ្វើការបណ្តុះបណ្តាល ផ្សព្វផ្សាយ និងការអប់រំដល់កសិករ អំពីការប្រើប្រាស់ពូជដែលមានគុណភាពខ្ពស់
- បោះពុម្ភ ផ្សព្វផ្សាយគោលនយោបាយនេះឱ្យបានទូលំទូលាយ ដើម្បីឱ្យគោលនយោបាយនេះ។

# ផ្នែកទី ១៩
# ការផ្តល់ហិរញ្ញប្បទានដល់វិស័យគ្រាប់ពូជ

- វិនិយោគភាគច្រើននឹងមានប្រភពពីវិស័យឯកជន នៅពេលដែលវិនិយោគិនទាំងនោះមើលឃើញពីកាលានុវត្តភាពល្អក្នុងការធ្វើពាណិជ្ជកម្ម

- ថវិកាដែលបានពីរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ត្រូវប្រើប្រាស់ជាចម្បងសម្រាប់ការងារជាយុទ្ធសាស្ត្រមួយចំនួនដូចជា បង្កាត់ពូជរុក្ខជាតិ និងការធ្វើពិសោធន៍ពូជដំណាំសំខាន់ៗ

- ថវិការដ្ឋត្រូវប្រើប្រាស់ផងដែរសម្រាប់ការធ្វើតេស្តពូជដំណាំ ការធ្វើបង្ហាញ និងការបណ្តុះបណ្តាលកសិករអំពីប្រពលវប្បកម្មដំណាំជាដើម

- ត្រូវរៀបចំយន្តការប្រមូលចំណូលពីការផ្តល់សេវាកម្មដែលបានផ្តលឱ្យអតិថិជនពេលដែលពួកគេប្រើប្រាស់សេវាកម្មនេះ

- ក្រុមការងារមួយ ត្រូវបានបង្កើតឡើងដោយមានតំណាងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងពាក់ព័ន្ធនានា និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ដើម្បីពិនិត្យកិច្ចការនេះឱ្យកាន់តែលម្អិតបន្ថែមទៀត និងលើកជាអនុសាសន៍សម្រាប់គាំទ្រដល់ការអភិវឌ្ឍន៍ឧស្សាហកម្មពូជដំណាំនៅកម្ពុជា

# ផ្នែកទី ១៥
# ទំនាក់ទំនងនិងសហប្រតិបត្តិការអន្តរជាតិ

- ដើម្បីតាមឱ្យទាន់ការអភិវឌ្ឍន៍ឧស្សាហកម្មពូជដំណាំក្នុងឆាកអន្តរជាតិ គ្រប់តួអង្គនានានៅកម្ពុជា ត្រូវសហការជិតស្និទ្ធជាមួយស្ថាប័ននានាទាំងថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ
- ត្រូវមានផ្តល់ការលើកទឹកចិត្តដល់ក្រុមហ៊ុនពូជដំណាំកម្ពុជាឱ្យចូលរួមក្នុងអង្គការឬស្ថាប័នឧស្សាហកម្មពូជដំណាំ ទាំងថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ
- នៅពេលដែលមានផលិតករ និងអ្នកជំនួញពូជដំណាំគ្រប់គ្រាន់ ត្រូវបង្កើតឱ្យមានសហគមន៍ពាណិជ្ជកម្មពូជដំណាំដើម្បីជាតំណាងវិស័យឯកជនក្នុងនាមជាដៃគូរជាមួយរដ្ឋាភិបាល និងចូលរួមកិច្ចប្រជុំសំខាន់ៗថ្នាក់តំបន់

ទោះបីជាយ៉ាងណាក៏ដោយ ការងារនេះអាស្រ័យលើការផ្តួចផ្តើម និងការប្តេជ្ញាចិត្តរបស់សមជិកនីមួយៗ ក្នុងការបង្កើតសហគមន៍ពាណិជ្ជកម្មពូជដំណាំនេះ។